# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៧៣

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១..**

ត្រូវបានបង្កើត **ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ដែលហៅកាត់ថា **ក.ស.វ.** ដែលជាស្ថាប័នការនៅអមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិក្សាស្រាវជ្រាវបញ្ហាប្រឈម និងពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយលើកយោបល់ជូនរាជរដ្ឋាភិបាល ។

## ជំពូកទី ២
## មុខងារ និងភារកិច្ច

**មាត្រា ២.-**

ក.ស.ឧ. មានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យតាមដានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលវិវត្តប្រចាំខែ និងប្រចាំឆ្នាំ ដោយប្រមូលទិន្នន័យនិងព័ត៌មានពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយធ្វើការវិភាគនិងរកមូលហេតុ រួចធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវលើប្រធានបទដែលជាបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជះឥទ្ធិពលលើការអភិវឌ្ឍប្រទេស និងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- ចុះធ្វើអង្កេតស្តីពីប្រធានបទពិសេសដែលរាជរដ្ឋាភិបាលឬទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន
- លើកយោបល់ជូនរាជរដ្ឋាភិបាលលើវាលវិធានការដោះស្រាយចាំបាច់នានា សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពវិវត្តនិងបញ្ហាប្រឈមក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ធ្វើការព្យាករស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលអាចកើតមានឡើងនាពេលអនាគត រួចផ្តល់យោបល់ជូនរាជរដ្ឋាភិបាល
- ពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព របាយការណ៍ កិច្ចព្រមព្រៀង និងឯកសារផ្សេងៗទៀត ដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល
- ចងក្រងទិន្នន័យនិងព័ត៌មានវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រួមទាំងឯកសារលិខិតបទដ្ឋានគតិយុត្តនានា តាមរយៈប្រព័ន្ធគ្រប់គ្រងពត៌មាន
- សហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងព័ត៌មាន
- រៀបចំសិក្ខាសាលានិងផ្តល់បទបង្ហាញលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាលឬទីស្តីការគណៈរដ្ឋមន្ត្រី ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ៣

## សមាសភាព

**មាត្រា ៣.-**

**គ.ស.ទ.** មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១. ឥស្សរជនជាន់ខ្ពស់មួយរូប | ជាប្រធាន |
| ២. ឥស្សរជនមួយចំនួន | ជាអនុប្រធាន |
| ៣. ឥស្សរជន ឬអ្នកជំនាញមួយចំនួន | ជាសមាជិក |
| ៤. អ្នកបច្ចេកទេសមួយចំនួនតាមតម្រូវការចាំបាច់ | ជាសមាជិកបម្រុង |

ប្រធាន អនុប្រធាន សមាជិក និងសមាជិកបម្រុងនៃ **គ.ស.ទ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៤.-**

**គ.ស.ទ.** ដឹកនាំដោយប្រធានមានឋានៈស្មើទេសរដ្ឋមន្ត្រីឬរដ្ឋមន្ត្រី ។

ប្រធាន **គ.ស.ទ.** ជាឥស្សរជនជាន់ខ្ពស់ដែលមានចំណេះវិជ្ជាកម្រិតឧត្តមសិក្សាឡើងទៅ មានសមត្ថភាព និងមានបទពិសោធខ្ពស់ក្នុងនិង/ឬក្រៅប្រទេស លើមុខជំនាញណាមួយ ជាអាទិ៍ខាងសេដ្ឋកិច្ច នយោបាយ រដ្ឋបាលសាធារណៈ ។

ប្រធាន **គ.ស.ទ.** មានអនុប្រធានមួយចំនួនសម្រាប់ជួយការងារ ដែលមានឋានៈស្មើរដ្ឋមន្ត្រី ។

អនុប្រធាន **គ.ស.ទ.** ជាឥស្សរជនដែលត្រូវមានគុណវុឌ្ឍិដូចប្រធាន **គ.ស.ទ.** ដែរ ។

**មាត្រា ៥.-**

សមាជិក **គ.ស.ទ.** ជាអ្នកជំនាញដែលត្រូវមានគុណវុឌ្ឍិដូចខាងក្រោម ៖

- មានចំណេះវិជ្ជាកម្រិតឧត្តមសិក្សាឡើងទៅ
- មានចំណេះដឹងទូទៅកម្រិតខ្ពស់
- មានបទពិសោធការងារក្នុងនិង/ឬក្រៅប្រទេស លើមុខជំនាញណាមួយច្បាស់លាស់ ជាអាទិ៍សេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋបាលសាធារណៈ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សេវាកម្ម
- មានការយល់ដឹងផ្នែកនយោបាយ ជាពិសេសនយោបាយរបស់រាជរដ្ឋាភិបាល ។

សមាជិក **គ.ស.ទ.** អាចមានឋានៈស្មើរដ្ឋមន្ត្រី រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សមាជិកបម្រុង **គ.ស.ទ.** ជាអ្នកបច្ចេកទេសកម្រិតខ្ពស់ពីគ្រប់វិស័យ មានសញ្ញាបត្របណ្ឌិតនិងមានបទពិសោធវិជ្ជាជីវៈយ៉ាងតិចពាឆ្នាំ ក្រោយទទួលបានសញ្ញាបត្របណ្ឌិត មានឋានៈស្មើអគ្គនាយក ។

**មាត្រា ៦..**

សមាជិក **គ.ស.ទ.** ចែកចេញជា សមាជិកអចិន្ត្រៃយ៍ និងសមាជិកមិនអចិន្ត្រៃយ៍ ។

សមាជិកអចិន្ត្រៃយ៍ជាសមាជិកដែលបម្រើការងារពេញម៉ោងនៅ **គ.ស.ទ.** ។

សមាជិកមិនអចិន្ត្រៃយ៍ជាសមាជិកដែលបម្រើការងារនៅក្រសួង ស្ថាប័នណាមួយ ហើយបំពេញការងារនៅ **គ.ស.ទ.** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ៧..**

**គ.ស.ទ.** អាចមានអ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញនិងមានបទពិសោធខ្ពស់ សម្រាប់ជួយការងារជាទីប្រឹក្សាបច្ចេកទេស ។

## ជំពូកទី ៤
## រចនាសម្ព័ន្ធ

**មាត្រា ៨..**

**គ.ស.ទ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់កិច្ចដំណើរការការងារប្រចាំថ្ងៃ ។

**មាត្រា ៩..**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ស.ទ.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## កិច្ចដំណើរការការងារ

**មាត្រា ១០..**

**គ.ស.ទ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ស.ទ.** ឬតាមសេចក្តីបង្គាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រីឬរាជរដ្ឋាភិបាល ។

**គ.ស.ទ.** មានសិទ្ធិអញ្ជើញតំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ជាថ្នាក់ដឹកនាំនិងថ្នាក់បច្ចេកទេស ឱ្យមកចូលរួមប្រជុំ ដើម្បីជួយបំភ្លឺនិងផ្តល់ព័ត៌មានពិស្តារបន្ថែមតាមការចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១១..**

គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធមានភារកិច្ចផ្ដល់ឯកសារ ទិន្នន័យ និងព័ត៌មាន ហើយផ្ដល់កិច្ចសហការយ៉ាងជិតស្និទ្ធជូន **ក.ស.ទ.** ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ ជូនទីស្ដីការគណៈរដ្ឋមន្ត្រីនិងរាជរដ្ឋាភិបាល។

**មាត្រា ១២..**

**ក.ស.ទ.** ត្រូវមានតំណាងចូលរួមប្រជុំក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយទីស្ដីការគណៈរដ្ឋមន្ត្រីឬដោយក្រសួង ស្ថាប័ននានា ដើម្បីអាចបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា២ខាងលើ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**មាត្រា ១៣..**

**ក.ស.ទ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី ៦

## ប្រភពធនធាន

**មាត្រា ១៤..**

**ក.ស.ទ.** មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**ក.ស.ទ.** មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ១៥..**

សមាសភាព រចនាសម្ព័ន្ធ និងមន្ត្រីបម្រើការងារនៅក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវផ្ទេរឱ្យទៅបម្រើការក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រោយពីព្រះរាជក្រឹត្យនេះចូលជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

អនុក្រឹត្យលេខ៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៩

**ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសព្វព្រះរាជហឫទ័យ**

**ប្រមុខរដ្ឋស្តីទី**

នស/រកត.០៩០២.១៧៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ១៧៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**